# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## សិក្ខាសាលាផ្សព្វផ្សាយ «ការជ្រើសរើសជំនាញសិក្សា និងស្វែងយល់ពីព័ត៌មានទីផ្សារការងារ»

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ប្អូនៗសិស្សានុសិស្ស ដែលទើបប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ និងអាណាព្យាបាលទាំងអស់ឱ្យបានជ្រាបថា ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយក្នុងការរៀបចំផែនការអាជីព និងជ្រើសរើសការសិក្សាប្រកបដោយប្រសិទ្ធភាព ក្រសួងសូមអញ្ជើញប្អូនៗសិស្សានុសិស្ស និងអាណាព្យាបាលទាំងអស់ ចូលរួមដោយឥតគិតថ្លៃក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី **«ការជ្រើសរើសជំនាញសិក្សា និងស្វែងយល់ពីព័ត៌មានទីផ្សារការងារ»** ដោយមានការចូលរួមពីវាគ្មិនដែលមានបទពិសោធច្រើនឆ្នាំក្នុងវិស័យការងារ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងព័ត៌មានទីផ្សារការងារ។

តាមរយៈកម្មវិធីនេះប្អូនៗសិស្សានុសិស្សនឹងទទួលបានព័ត៌មានជាមូលដ្ឋាន ឱកាសក្នុងការសាកសួរនិងពិគ្រោះយោបល់ផ្ទាល់ពីវាគ្មិនកិត្តិយស ក្នុងការសម្រេចចិត្តជ្រើសរើសសិក្សាជំនាញណាមួយ ការរៀបចំផែនការអាជីព និងការងារ ស្របតាមតម្រូវការទីផ្សារការងារទាំងនាពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងចំណូលចិត្ត និងបុគ្គលិកលក្ខណៈរបស់ខ្លួនៗ។ លើសពីនេះ ក្រសួងនឹងមានផ្តល់អាហារូបករណ៍១០០% ចំនួន ១០កន្លែង និង៥០% ចំនួន ១០កន្លែងសម្រាប់អ្នកដែលបានមកចូលរួមផ្ទាល់ តាមរយៈការចាប់ឆ្នោតក្រោយចប់កម្មវិធី។

សិក្ខាសាលានេះនឹងប្រព្រឹត្តទៅនៅ***ព្រឹកថ្ងៃសុក្រ ទី២៨ ខែសីហា ឆ្នាំ២០២៦*** នៅសាលប្រជុំក្រវ៉ាន់ អគារអង្គរវត្ត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI)(សូមភ្ជាប់ជូន QR Code) ***វេលាម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១១:០០នាទីព្រឹក***។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ឬតាមរយៈលេខទូរសព្ទ ***០៩៨ ៩៨៧ ៧៧៩ / ០១៧ ៧៤៧ ៧៧៣***។ សូមបំពេញព័ត៌មានតាមរយៈតំណភ្ជាប់ https://forms.gle/UTBP9NbGh61DK8AR7 នេះ ឬស្កេន QR Code ខាងក្រោមដើម្បីស្នើសុំចូលរួមសិក្ខាសាលាខាងលើដោយឥតគិតថ្លៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមប្អូនៗសិស្សានុសិស្សដែលទើបប្រឡងបញ្ចប់ និងអាណាព្យាបាលទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមដោយសេរីក្នុងសិក្ខាសាលាដ៏មានសារសំខាន់នេះឱ្យបានច្រើនកុះករ។

ថ្ងៃ ចន្ទ ១១កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២៦

សូមស្កេនរកទីតាំង

ស្កេនដើម្បីចុះឈ្មោះ